**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ [illegible]

ថ្ងៃ ចន្ទ ១៣រោច ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ តុលា ឆ្នាំ២០២១

**ជម្រាបជូន**
**លោកបណ្ឌិត សរ ចិត្រា អគ្គលេខាធិការរង និងជានាយកគម្រោងពិពិធកម្មកសិកម្មកម្ពុជា**
**នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** ស្នើសម្របសម្រួលផ្តល់ដំណឹងជូន "**សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ**" និង "**សហគមន៍កសិកម្មសាមគ្គីរុងរឿង**" ពីលទ្ធផលនៃការវាយតម្លៃសំណើពិពិធកម្មនិងធុរកិច្ច ក្រោមក្របខ័ណ្ឌគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP)។

**ភ្ជាប់ជូន៖** -របាយការណ៍ពិនិត្យនិងអនុម័តរបស់ AEC ចំនួន ០១ ច្បាប់,
-របាយការណ៍វាយតម្លៃរបស់ EC លើសំណើពិពិធកម្មនិងធុរកិច្ច ចំនួន ០១ ច្បាប់។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាប **លោកបណ្ឌិត** ឱ្យបានជ្រាបថា៖ កាលពីថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០២១ គណៈកម្មការប្រឹក្សាយោបល់និងអនុម័ត (AEC) បានបើកកិច្ចប្រជុំពិនិត្យ និងអនុម័តលើរបាយការណ៍វាយតម្លៃសំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍ចំនួន ២ គឺ "**សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ**" និង "**សហគមន៍កសិកម្មសាមគ្គីរុងរឿង**" ដែលបានរៀបចំដោយគណៈកម្មការវាយតម្លៃ (EC)។ យោងតាមលទ្ធផលនៃការវាយតម្លៃ បានបង្ហាញថា សំណើពិពិធកម្មនិងធុរកិច្ចរបស់ "**សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ**" ទទួលបានពិន្ទុសរុបចំនួន **៧១,៣០** ពិន្ទុ, ចំណែកឯ "**សហគមន៍កសិកម្មសាមគ្គីរុងរឿង**" ទទួលបានពិន្ទុសរុបចំនួន **៧០,៦០** ពិន្ទុ ដោយបានបំពេញលក្ខខ័ណ្ឌគ្រប់គ្រាន់ និងអាចបន្តទៅដំណាក់កាលបន្ទាប់ក្នុងការរៀបចំសរសេរផែនការពិពិធកម្មនិងធុរកិច្ច។ គណៈកម្មការប្រឹក្សាយោបល់និងអនុម័ត ក៏បានពិនិត្យ និងឯកភាពលើលទ្ធផលនៃការវាយតម្លៃរបស់គណៈកម្មការ EC ផងដែរ។

ក្នុងន័យនេះ ដើម្បីបំពេញតាមនីតិវិធីនៃការអនុវត្តគម្រោង, ខ្ញុំសូមស្នើ អង្គភាពសម្របសម្រួលគម្រោងពិពិធកម្មកសិកម្មកម្ពុជា (Project Coordination Office-PCO) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្របសម្រួលផ្តល់ដំណឹងជូន "**សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ**" និង "**សហគមន៍កសិកម្មសាមគ្គីរុងរឿង**" អំពីលទ្ធផលដូចមានរបាយការណ៍ភ្ជាប់ជូន និងរៀបចំចុះផ្សាយក្នុងគេហទំព័ររបស់គម្រោងសម្រាប់ជាព័ត៌មានបន្ថែម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកបណ្ឌិត** ពិនិត្យ និងចាត់ចែង តាមការគួរ។
សូម **លោកបណ្ឌិត** ទទួលនូវការរាប់អានពីខ្ញុំ។

**អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការប្រឹក្សាយោបល់និងអនុម័ត នៃគម្រោង CASDP**

**ឆេត គីយៀវិន្ទ**

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855)23 890 666

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
អង្គភាពអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា

# របាយការណ៍កិច្ចប្រជុំ
# គណៈកម្មការប្រឹក្សាយោបល់ និងអនុម័ត នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា

## ១. កម្មវត្ថុនៃកិច្ចប្រជុំ

នៅថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០២១, គណៈកម្មការប្រឹក្សាយោបល់និងអនុម័ត (Advisory and Endorsement Committee-AEC) នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា (Cambodia Agricultural Sector Diversification Project-CASDP) បានបើកកិច្ចប្រជុំពិនិត្យ និងអនុម័តលើរបាយការណ៍វាយតម្លៃសំណើពិពិធកម្មនិងធុរកិច្ច (DPr) របស់ "**សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ**" និង "**សហគមន៍កសិកម្មសាមគ្គីរុងរឿង**" ដែលបានរៀបចំឡើងដោយគណៈកម្មការវាយតម្លៃ (Evaluation Committee-EC) កាលពីថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០២១ កន្លងទៅ។ កិច្ចប្រជុំនេះ រៀបចំឡើងក្នុងគោលបំណងសម្រេចជាផ្លូវការ ដើម្បីផ្តល់លទ្ធភាពឱ្យសហគមន៍កសិកម្មបន្តរៀបចំផែនការពិពិធកម្មនិងធុរកិច្ចលម្អិត មុននឹងផ្តល់ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគដល់សហគមន៍។

## ២. សមាសភាពអង្គប្រជុំ

កិច្ចប្រជុំគណៈកម្មការ AEC ត្រូវបានរៀបចំឡើងដោយអង្គភាពអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF-PIU/CASDP) ក្រោមអធិបតីភាព **ឯកឧត្តម ទេព តិយ៉ោវិទ្រ្ន** អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការ AEC ព្រមទាំងមានការចូលរួមពីសំណាក់សមាជិកនៃគណៈកម្មការចំនួន ០៧ រូប រួមមាន ÷ ឯកឧត្តម **ជ្រាយ ប៉ុម**, លោកបណ្ឌិត **សរ ចិត្រា**, លោក **សុខ ខន**, លោក **អ៊ឹម សួស្តី**, លោកឧកញ៉ា **ហង់ សុគន្ធ**, ឯកឧត្តម **ម៉េង និមល** និងលោក **ផល វ៉ាន់ឌី** (តំណាងឱ្យលោក តា បូរាណ)។

## ៣. លទ្ធផលនៃកិច្ចប្រជុំ និងផែនការសកម្មភាព

ជាកិច្ចចាប់ផ្តើម **ឯកឧត្តម ទេព តិយ៉ោវិទ្រ្ន** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មការ AEC បានថ្លែងនូវមតិស្វាគមន៍ដល់សមាជិកនៃអង្គប្រជុំទាំងមូល និងបានបញ្ជាក់ពីគោលបំណងសំខាន់ៗនៃកិច្ចប្រជុំនេះ ព្រមទាំងបានផ្តល់សារគន្លឹះមួយចំនួនពាក់ព័ន្ធនឹងការពិនិត្យ និងអនុម័តលើរបាយការណ៍វាយតម្លៃសំណើពិពិធកម្មនិងធុរកិច្ច របស់ "**សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ**" និង "**សហគមន៍កសិកម្មសាមគ្គីរុងរឿង**" ដែលបានរៀបចំដោយគណៈកម្មការ EC កាលពីថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០២១។

ជាកិច្ចបន្ទាប់ **លោក ឡៅ ប៉ូលីវេត** អនុប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ និងជាប្រធានគណៈកម្មការ EC បានធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំដោយសង្ខេបអំពីសារតា និងលទ្ធផលនៃការវាយតម្លៃសំណើ DPr ដូចខាងក្រោម÷

**១. សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ** មានទីតាំងស្ថិតនៅភូមិថ្កែង ឃុំរហ័ស ស្រុករវៀង ខេត្តព្រះវិហារ បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ តាមរយៈលិខិតចុះបញ្ជីលេខ ០១៨ ម.កសក.ពហ ដែលមានវិញ្ញាបនបត្រលេខ ០០៧ ម.កសក.ពហ/ស.ក.ក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១២។

- សំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍ គឺផ្តោតលើ **"ពង្រីកទីផ្សារទិញ-លក់គ្រាប់ស្វាយចន្ទីសរីរាង្គ"** ដែលមានសមាជិកក្រុមផលិតសរុប ៨០ នាក់ ក្នុងនោះមានស្ត្រីចំនួន ០២ នាក់(មិនមានជនជាតិដើមភាគតិចទេ)។
- ផែនការថវិកា ដែលគ្រោងប្រើប្រាស់សម្រាប់ការពង្រីកទីផ្សារទិញ-លក់គ្រាប់ស្វាយចន្ទីសរីរាង្គនេះ សរុបមានចំនួន **៣០៦ ៧៩៣** ដុល្លារអាមេរិក ក្នុងនោះ សហគមន៍គ្រោងស្នើសុំហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ៤៧ ៦៣៤ ដុល្លារអាមេរិក, ស្នើសុំកម្ចីពីធនាគារឯកជនដែលសហការជាមួយគម្រោង CASDP សរុប ២១៧ ៩០៧ ដុល្លារអាមេរិក និងថវិកាបដិភាគពីសមាជិកក្រុមផលិតសរុប ៤១ ២៥២ ដុល្លារអាមេរិក។
- លទ្ធផលនៃការវាយតម្លៃលើ សំណើពិពិធកម្មនិងធុរកិច្ចរបស់ **"សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ"** ទទួលបាន ពិន្ទុចំនួន **៧១.៣០ ពិន្ទុ** លើពិន្ទុសរុប ១០០ ពិន្ទុ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបន្តរៀបចំផែនការពិពិធកម្មនិងធុរកិច្ច។

**២. សហគមន៍កសិកម្មសាមគ្គីរុងរឿង** មានទីតាំងស្ថិតនៅភូមិថ្មល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ តាមរយៈលិខិតចុះបញ្ជីលេខ ០២៤ ម.កសក.ពហ ដែលមានវិញ្ញាបនបត្របញ្ជាក់លេខ ០១៣ ម.កសក.ពហ/ស.ក.ក ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០១៣។

- សំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍ គឺផ្តោតលើ **"ពង្រីកទីផ្សារទិញ-លក់គ្រាប់ស្វាយចន្ទីសរីរាង្គ"** ដែលមានសមាជិកក្រុមផលិតសរុប ៦៤ នាក់ ក្នុងនោះ ពុំមានស្ត្រីទេ(មិនមានជនជាតិដើមភាគតិចទេ)។
- ផែនការថវិកា ដែលគ្រោងប្រើប្រាស់សម្រាប់ការពង្រីកទីផ្សារទិញ-លក់គ្រាប់ស្វាយចន្ទីសរីរាង្គនេះ សរុបមានចំនួន **៣១២ ៩០៦** ដុល្លារអាមេរិក ក្នុងនោះ សហគមន៍គ្រោងស្នើសុំហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ៤៧ ៤៥៣ ដុល្លារអាមេរិក, ស្នើសុំកម្ចីពីធនាគារឯកជនដែលសហការជាមួយគម្រោង CASDP សរុប ២១៩ ៣៨៤ ដុល្លារអាមេរិក និងថវិកាបដិភាគពីសមាជិកក្រុមផលិតសរុប ៤៦ ០៧០ ដុល្លារអាមេរិក។

- លទ្ធផលនៃការវាយតម្លៃលើ សំណើពិពិធកម្មនិងធុរកិច្ចរបស់ “**សហគមន៍កសិកម្មសាមគ្គីរុងរឿង**” ទទួលបាន ពិន្ទុចំនួន **៧០.៦០ ពិន្ទុ** លើពិន្ទុសរុប ១០០ ពិន្ទុ និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបន្តរៀបចំផែនការពិពិធកម្មនិងធុរកិច្ច។

ក្រោយពីសេចក្តីរាយការណ៍បានបញ្ចប់ អង្គប្រជុំបានធ្វើការពិនិត្យ និងពិភាក្សាលើរបាយការណ៍ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនីមួយៗ ដោយទទួលបានលទ្ធផលចំនួនសម្លេង ៨ លើ ៨ ក្នុងការសម្រេចគាំទ្រ និងឯកភាពលើរបាយការណ៍វាយតម្លៃរបស់គណៈកម្មការ EC។ អង្គប្រជុំក៏បានស្នើឱ្យសហគមន៍ទាំងពីរខាងលើ បន្តយកចិត្តទុកដាក់និងពិនិត្យឱ្យបានម៉ត់ចត់ នៅពេលរៀបចំផែនការពិពិធកម្មកនិងធុរកិច្ច នៅជំហានបន្ទាប់ ដែលពាក់ព័ន្ធនឹងចំណុចដូចខាងក្រោម÷

- **ពិនិត្យមើលឡើងវិញនូវប្រភេទវិនិយោគដែលបានស្នើឡើង ដោយត្រូវធានាថាប្រភេទវិនិយោគដែលស្នើឡើងមានផលិតភាពនឹងអាចសម្រេចបាននូវគោលដៅដែលបានកំណត់នៅក្នុងសំណើ** ទាំងក្នុងកម្រិតសហគមន៍ និងកម្រិតកសិដ្ឋាន ជាពិសេស ការទិញរថយន្ត, ត្រាក់ទ័រ និងគោយន្ត ដែលការវិនិយោគទាំងនេះ គឺមានផលិតភាពតិចតួចក្នុងការសម្រេចគោលដៅនៃសំណើ។
- **ពិនិត្យមើលឡើងវិញលើបរិមាណផលិត និងតម្រូវការបញ្ជាទិញ** ដោយត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីផែនការផលិត និងបរិមាណបញ្ជាទិញ និងចំណែកតម្រូវការទីផ្សារផ្សេងទៀត។ ទន្ទឹមនេះ ត្រូវតែធានាថាការបញ្ជាទិញមានបរិមាណច្រើនជាង ឬ ស្មើនឹងផែនការផលិតរបស់សហគមន៍។
- **ផ្តល់ការវិភាគលើតម្លៃប្រៀបធៀបពីផលចំណេញនៃការទិញ-លក់បច្ចុប្បន្ន** ជាមួយ **ផលចំណេញនៃតម្លៃបន្ថែមពីការវិនិយោគរបស់គម្រោង** (ឧ. ការទិញ-លក់ដោយមិនមានលាងសម្អាត ធៀបទៅនឹង ការទិញ-លក់ដោយមានការលាងសម្អាត)។
- **សហគមន៍គួរសម្របសម្រួលឱ្យមានការលក់រួមគ្នា** ដែលអាចជួយបន្ធូរបន្ថយបញ្ហាកង្វះទុនប្រតិបត្តិការរបស់សហគមន៍កសិកម្មក្នុងការទិញគ្រាប់ស្វាយចន្ទីពីសមាជិក។

ជាមួយគ្នានេះដែរ អង្គប្រជុំក៏បានយល់ព្រមផ្តល់លទ្ធផលនៃកិច្ចប្រជុំនេះ ជូនទៅអង្គភាពសម្របសម្រួលគម្រោងពិពិធកម្មកសិកម្មកម្ពុជា (Project Coordination Office-PCO) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសម្របសម្រួលផ្តល់ដំណឹងជូន “**សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ**” និង “**សហគមន៍កសិកម្មសាមគ្គីរុងរឿង**” អំពីលទ្ធផលនៃការវាយតម្លៃសំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍ និងចុះផ្សាយលទ្ធផលនេះក្នុងគេហទំព័ររបស់គម្រោង ផងដែរ។

ជាកិច្ចបញ្ចប់ **ឯកឧត្តម ទេព តិយ៉ោវិទ្ធ** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានគណៈ-កម្មការ AEC បានថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំទាំងអស់ដែលបានចូលរួម និងស្នើសុំសមាជិកទាំងអស់បន្តចូលរួមកិច្ចប្រជុំបន្ទាប់ដែលគ្រោងរៀបចំឡើង **នៅថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០២១ វេលាម៉ោង ១៥ :០០ នាទី** ដើម្បីបន្តពិនិត្យ និងអនុម័តលើសំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍ចំនួន ២ គឺ “**សហគមន៍កសិកម្មរមទមសាមគ្គីមានជ័យ**” និង “**សហគមន៍**

**កសិកម្មរស្មីលើកកម្ពស់កសិករ"** ។ **ឯកឧត្តមអនុរដ្ឋលេខាធិការ** ប្រធានអង្គប្រជុំ បានប្រកាសបិទអង្គប្រជុំនៅថ្ងៃដដែល វេលាម៉ោង ១៧ : ០០ នាទី។

ថ្ងៃចន្ទ ១៤ កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១

**លេខាធិការ**

**នៃគណៈកម្មការប្រឹក្សាយោបល់ និងអនុម័ត AEC**

**ឌី សេរីវីរៈ**

ថ្ងៃ សុក្រ ១០រោច ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ តុលា ឆ្នាំ២០២១

**យល់ព្រម**

**អនុរដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មការប្រឹក្សាយោបល់ និងអនុម័ត AEC**

**ទេព ភិរម្យវិទ្ធ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អង្គភាពអនុវត្តគម្រោងពិពិធកម្មកសិកម្មកម្ពុជា

# របាយការណ៍កិច្ចប្រជុំ

## គណៈកម្មការវាយតម្លៃ នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា

### ១. កម្មវត្ថុនៃកិច្ចប្រជុំ

នៅថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ ២០២១, គណៈកម្មការវាយតម្លៃ (Evaluation Committee-EC) នៃគម្រោងពិពិធកម្មកសិកម្មកម្ពុជា (Cambodia Agricultural Sector Diversification Project-CASDP) បានបើកកិច្ចប្រជុំពិនិត្យ, វាយតម្លៃ និងដាក់ពិន្ទុ លើសំណើពិពិធកម្មនិងធុរកិច្ចរបស់ "**សហគមន៍កសិកម្មសាមគ្គីរហ៍សមានជ័យ**" និង "**សហគមន៍កសិកម្មសាមគ្គីរុងរឿង**" មុននឹងបញ្ជូនបន្តទៅកាន់គណៈកម្មការប្រឹក្សាយោបល់និងអនុម័ត (Advisory and Endorsement Committee-AEC) ដើម្បីពិនិត្យ និងអនុម័តជាផ្លូវការ ដើម្បីអនុញ្ញាតឱ្យសហគមន៍កសិកម្មរៀបចំផែនការពិពិធកម្មនិងធុរកិច្ចបន្តទៀត។

### ២. សមាសភាពអង្គប្រជុំ

កិច្ចប្រជុំត្រូវបានដឹកនាំដោយ **លោក ឡៅ ប៉ូលីវេត** អនុប្រធាននាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ និងជាប្រធានគណៈកម្មការវាយតម្លៃ(EC) ដោយមានការចូលរួមពីសមាជិក និងសមាជិកានៃគណៈកម្មការចំនួន ០៧រូប រួមមាន÷ ១. លោក **ហុក គីមធួន**, ២. លោក **ឆេង វិបុលរិទ្ធ**, ៣. លោក **ទិត្យ សុជា**, ៤. លោក **សុខ បូរ៉ែន**, ៥. លោក **ដុក លួន**, ៦. លោកស្រី **ជា សុខអ៊ីម** និង ៧. លោកស្រី **ហ៊ីង លីហួង**(តំណាងឱ្យលោក សុខ រឿន)។

### ៣. សេចក្តីសង្ខេបពីសំណើពិពិធកម្ម និងធុរកិច្ច

**១. សហគមន៍កសិកម្មសាមគ្គីរហ៍សមានជ័យ** មានទីតាំងស្ថិតនៅភូមិថ្លែង ឃុំរហ័ស ស្រុករវៀង ខេត្តព្រះវិហារ។ សហគមន៍និងក្រុមផលិតចំនួន១ ក្រុម បានចូលរួមដាក់សំណើ (ពង្រីកទីផ្សារទិញ-លក់គ្រាប់ស្វាយចន្ទីសរីរាង្គ) ដែលមានសមាជិកក្រុមផលិតសរុប ៨០ នាក់ ក្នុងនោះមានស្ត្រីចំនួន ០២ នាក់ (មិនមានជនជាតិដើមភាគតិចទេ)។ សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យបានដំណើរការផលិតស្វាយចន្ទីសរីរាង្គចាប់ពីឆ្នាំ ២០១៨ រហូតដល់បច្ចុប្បន្ន, មានផ្ទៃដីដាំដុះស្វាយចន្ទីសរីរាង្គសរុប ១៦១,៥៥ ហិកតា ដែលទទួលបានបរិមាណផលសរុប ៨៦ តោន ក្នុងមួយឆ្នាំ (គ្រាប់ស្វាយចន្ទីសរីរាង្គស្ងួត ដែលមានសំណើមចន្លោះពី ៧% ទៅ ៨%)។ សហគមន៍ បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ

តាមរយៈលិខិតចុះបញ្ជីលេខ ០១៨ ម.កសក.ពហ ដែលមានវិញ្ញាបនបត្រលេខ ០០៧ ម.កសក.ពហ/ស.ក.ក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ ២០១២។ សហគមន៍មានមុខរបរចម្បងៗដែលកំពុងដំណើរការសព្វថ្ងៃរួមមាន÷ អាជីវកម្មប្រមូលទិញ-លក់គ្រាប់ស្វាយចន្ទីសរីរាង្គ ស្រូវសរីរាង្គ និងលក់ជីសរីរាង្គ។

ក្រោយពីទទួលបានព័ត៌មានពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP), សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ បានរៀបចំសំណើពិពិធកម្មនិងធុរកិច្ច មានតម្រូវការទឹកប្រាក់សរុបចំនួន ៣០៦ ៧៩៣ ដុល្លារអាមេរិក ដោយផ្ដោតលើការ "**ពង្រីកទីផ្សារទិញ-លក់គ្រាប់ស្វាយចន្ទីសរីរាង្គ**" ដើម្បីធ្វើឱ្យប្រសើរឡើងនូវច្រវាក់តម្លៃគ្រាប់ស្វាយចន្ទីសរីរាង្គ នៅលើទីផ្សារឱ្យកាន់តែមានតម្លៃខ្ពស់ ដោយការរក្សាបាននូវបរិមាណ គុណភាព និងតម្លៃស្របតាមការចុះកិច្ចសន្យាទិញ-លក់ ជាមួយក្រុមហ៊ុនស៊ីអេស៊ីស៊ី ដាក់ជូន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធធ្វើការពិនិត្យ ពិចារណា និងគាំទ្រហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ។

គោលដៅរួមនៃសំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ គឺបង្កើននូវបរិមាណនៃការផ្គត់ផ្គង់គ្រាប់ស្វាយចន្ទីសរីរាង្គ ឱ្យទៅក្រុមហ៊ុនបញ្ជាទិញសរុបចំនួន ៨៦ តោន នៅឆ្នាំ ២០២២ (ប្រាក់ចំណូលសរុប ១៥៧ ៤៦៦ ដុល្លារអាមេរិក) សរុបចំនួន ៩៥ តោន នៅឆ្នាំ ២០២៣ (ប្រាក់ចំណូលសរុប ១៧៣ ៩៤៥ ដុល្លារអាមេរិក) និងសរុបចំនួន ១០២ តោន (ប្រាក់ចំណូលសរុប ១៨៦ ៧៦២ ដុល្លារអាមេរិក) នៅឆ្នាំ ២០២៤ ក្នុងនោះមានប្រភពថវិកាដូចខាងក្រោម÷

- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ៤៧ ៦៣៤ ដុល្លារអាមេរិក
- កម្ចីពីធនាគារឯកជនដែលសហការជាមួយគម្រោង CASDP សរុប ២១៧ ៩០៧ ដុល្លារអាមេរិក
- ទុនបដិភាគពីសមាជិកក្រុមផលិត សរុប ៤១ ២៥២ដុល្លារអាមេរិក។

**២. សហគមន៍កសិកម្មសាមគ្គីរុងរឿង** មានទីតាំងស្ថិតនៅភូមិថ្មល់កែង ឃុំរុងរឿង ស្រុករវៀង ខេត្តព្រះវិហារ។ សហគមន៍និងក្រុមផលិតចំនួន ១ ក្រុម បានរួមគ្នាដាក់សំណើ (ពង្រីកទីផ្សារទិញ-លក់គ្រាប់ស្វាយចន្ទីសរីរាង្គ) ដែលមានសមាជិកក្រុមផលិតសរុប ៦៤ នាក់ ក្នុងនោះពុំមានស្ត្រីទេ (មិនមានជនជាតិដើមភាគតិចទេ)។ សហគមន៍កសិកម្មសាមគ្គីរុងរឿង បានដំណើរការផលិតគ្រាប់ស្វាយចន្ទីសរីរាង្គ ចាប់ពីឆ្នាំ ២០១៨ រហូតដល់បច្ចុប្បន្ន, មានផ្ទៃដីដាំដុះស្វាយចន្ទីសរីរាង្គសរុប ២០៦ ហិកតា ដែលទទួលបានបរិមាណផលរំពឹងទុកសរុប ១២៣ តោន ក្នុងមួយឆ្នាំ (គ្រាប់ស្វាយចន្ទីសរីរាង្គស្ងួត ដែលមានសំណើមចន្លោះពី ៧% ទៅ ៨%)។ សហគមន៍ បានចុះបញ្ជីទទួលស្គាល់ជាផ្លូវការដោយមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តព្រះវិហារ តាមរយៈលិខិតចុះបញ្ជីលេខ ០២៤ ម.កសក.ពហ ដែលមានវិញ្ញាបនបត្របញ្ជាក់លេខ ០១៣ ម.កសក.ពហ/ស.ក.ក ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០១៣។ សហគមន៍កសិកម្មមានមុខរបរចម្បងៗដែលកំពុងដំណើរការសព្វថ្ងៃរួមមាន÷ អាជីវកម្មប្រមូលទិញ-លក់គ្រាប់ស្វាយចន្ទីសរីរាង្គនិងស្រូវសរីរាង្គ និងលក់ជីសរីរាង្គ។

ក្រោយពីទទួលបានព័ត៌មានពីគម្រោងពិពិធកម្មកសិកម្មកម្ពុជា (CASDP), សហគមន៍កសិកម្មសាមគ្គីរុងរឿង បានរៀបចំសំណើពិពិធកម្មនិងធុរកិច្ច មានតម្រូវការទឹកប្រាក់សរុបចំនួន ៣១២ ៩០៦ ដុល្លារអាមេរិក ដោយផ្ដោតលើការ "**ពង្រីកទីផ្សារទិញ-លក់គ្រាប់ស្វាយចន្ទីសរីរាង្គ**" ដើម្បីធ្វើឱ្យប្រសើរឡើងនូវច្រវាក់តម្លៃគ្រាប់ស្វាយចន្ទីសរីរាង្គ នៅលើទីផ្សារឱ្យកាន់តែមានតម្លៃខ្ពស់ ដោយរក្សាបាននូវបរិមាណ គុណភាព និងតម្លៃស្របតាមការចុះកិច្ចសន្យាទិញ-លក់ ជាមួយក្រុមហ៊ុនស៊ីអេស៊ីស៊ី ដើម្បីដាក់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងពាក់ព័ន្ធធ្វើការពិនិត្យ ពិចារណា និងគាំទ្រហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគ។

គោលដៅរួមនៃសំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍កសិកម្មសាមគ្គីរុងរឿង គឺបង្កើននូវបរិមាណ នៃការផ្គត់ផ្គង់គ្រាប់ស្វាយចន្ទីសរីរាង្គ ឱ្យទៅក្រុមហ៊ុនបញ្ចាទិញសរុបចំនួន ១១៧ តោន នៅឆ្នាំ ២០២២ (ប្រាក់ចំណូលសរុប ២១៤ ២២៧ ដុល្លារអាមេរិក) បរិមាណសរុប ១២៧ តោន នៅឆ្នាំ ២០២៣ (ប្រាក់ចំណូលសរុប ២៣២ ៥៣៧ ដុល្លារអាមេរិក) និងបរិមាណសរុប ១៣២ តោន (ប្រាក់ចំណូលសរុប ២៤១ ៦៩២ ដុល្លារអាមេរិក) នៅឆ្នាំ២០២៤ ក្នុងនោះមានប្រភពថវិកាដូចខាងក្រោម÷

- ហិរញ្ញប្បទានឥតសំណងបំពេញបន្ថែមទុនវិនិយោគពីគម្រោង CASDP សរុប ៤៧ ៤៥៣ ដុល្លារអាមេរិក
- កម្ចីពីធនាគារឯកជនដែលសហការជាមួយ គម្រោង CASDP សរុប ២១៩ ៣៨៤ ដុល្លារអាមេរិក
- ទុនបដិភាគពីសមាជិកក្រុមផលិត សរុប ៤៦ ០៧០ ដុល្លារអាមេរិក។

## ៤. នីតិវិធីនៃការវាយតម្លៃ និងដាក់ពិន្ទុ លើសំណើពិពិធកម្ម

ការដាក់ពិន្ទុលើសំណើពិពិធកម្មនិងធុរកិច្ច (DPr) ត្រូវបានធ្វើឡើងដោយសមាជិកគណៈកម្មការ EC ម្នាក់ៗ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យជាគោលចំនួន ៧ ចំណុច រួមមាន÷ ១) ភាពពាក់ព័ន្ធរបស់ DPr ជាមួយក្របខ័ណ្ឌគម្រោង, ២) បទពិសោធន៍របស់តួអង្គពាក់ព័ន្ធក្នុងការប្រកបអាជីវកម្ម, ៣) ការរៀបចំ DPr/BPr, ៤) ឧបសគ្គ និងហានិភ័យដែលនឹងត្រូវធ្វើការឆ្លើយតប, ៥) ការវិភាគហិរញ្ញវត្ថុ, ៦) ផលជះផ្នែកបរិស្ថាន និង ៧) ផលជះផ្នែកសង្គមរបស់គម្រោង។ សមាជិកម្នាក់ធ្វើការដាក់ពិន្ទុលើសំណើ ចន្លោះពី ១ ទៅ ១០០ ពិន្ទុ លើសំណើពិពិធកម្ម ម្តងមួយៗ។ ទន្ទឹមនេះ ពិន្ទុដែលផ្តល់ដោយសមាជិកម្នាក់ៗ នៃគណៈកម្មការវាយតម្លៃ មិនត្រូវបានអនុញ្ញាតឱ្យចែករំលែកដល់សមាជិកគណៈកម្មការដ៏ទៃទៀតដឹងនោះឡើយ។ សំណើពិពិធកម្មមួយដែលត្រូវបានវាយតម្លៃដោយសមាជិកគណៈកម្មការ EC ចំនួន ៨ រូប គឺអាចមានពិន្ទុអតិបរមាត្រឹម ៨០០ ពិន្ទុ។

## ៥. លទ្ធផលនៃការវាយតម្លៃ និងដាក់ពិន្ទុ

តាមរយៈការធ្វើមធ្យមភាគ នៃពិន្ទុទាំងអស់របស់សមាជិកគណៈកម្មការ EC លើសំណើពិពិធកម្មនិងធុរកិច្ចរបស់សហគមន៍កសិកម្មទាំងពីរខាងលើនេះ បានបង្ហាញឱ្យឃើញថា ពិន្ទុសរុបជាមធ្យមនៃ “**សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ**” ទទួលបានពិន្ទុ ចំនួន **៧១.៣០** លើពិន្ទុសរុប ១០០។ ចំណែកឯ “**សហគមន៍កសិកម្មសាមគ្គីរុងរឿង**” ទទួលបានពិន្ទុចំនួន **៧០.៦០** លើពិន្ទុសរុប ១០០។

ការវាយតម្លៃតាមលក្ខណៈវិនិច្ឆ័យរបស់សមាជិកគណៈកម្មការ EC ម្នាក់ៗ មានខ្លឹមសារលម្អិតក្នុងតារាងខាងក្រោម÷

# គណៈកម្មការវាយតម្លៃ "សំណើពិពិធកម្មនិងធុរកិច្ច របស់សហគមន៍សាមគ្គីរស់មានជ័យ"

| ល.រ | ចំណុចត្រូវវាយតម្លៃ | ពិន្ទុអតិបរមា | ពិន្ទុផ្ដល់ដោយសមាជិក | | | | | | | | | សេចក្ដីពន្យល់ពីការដាក់ពិន្ទុ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | EC1 | EC2 | EC3 | EC4 | EC5 | EC6 | EC7 | EC8 | Average Score | |
| **១. ភាពពាក់ព័ន្ធនៃDPr ជាមួយក្របខ័ណ្ឌគម្រោង** | | | | | | | | | | | | |
| | ១.១. សនិទានភាព (ហេតុផល) និងគោលបំណង DPr ដែលរៀបចំសរសេរបានល្អ<br>The rationale and objectives of the proposed DPr are well formulated | 5 | 4 | 4 | 4 | 3 | 4 | 4 | 4 | 3 | 3.8 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially)= ៤<br>ល្អ (good) = ៣;<br>ខ្លះៗ (Some) = ២,<br>ខ្សោយ (poor) = ១ |
| | ១.២. ភាពពាក់ព័ន្ធរបស់DPr នេះ នឹងជួយឱ្យសម្រេចគោលបំណងគម្រោង CASDP<br>The relevance of the proposed DPr to reach the objective of the CASDP project | 5 | 4 | 4 | 4 | 4 | 4 | 4 | 4 | 4 | 4.0 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥;<br>ល្អប្រសើរ (substantially) = ៤;<br>ល្អ (good) = ៣;<br>ខ្លះៗ (some) = ២,<br>ខ្សោយ (poor) = ១ |
| **២. បទពិសោធន៍របស់តួអង្គពាក់ព័ន្ធ** | | | | | | | | | | | | |
| | ២.១. ចំនួនឆ្នាំពិតជាមធ្យមនៃការប្រកបអាជីវកម្មរបស់ក្រុមផលិត និងកសិករពាណិជ្ជកម្ម និងសមាគម ដែលបានចុះបញ្ជី Average year of legal constitution of POs and SMAs | 5 | 4 | 4 | 4 | 5 | 4 | 4 | 4 | 4 | 4.1 | លើសពី ៣ ឆ្នាំ = ៥;<br>ចន្លោះពី ២ ទៅ ៣ ឆ្នាំ = ៤;<br>ចន្លោះពី ១ ទៅ ២ ឆ្នាំ = ៣;<br>ចន្លោះពី ០,៥ ទៅ ១ ឆ្នាំ = ២;<br>តិចជាង ០,៥ ឆ្នាំ = ១ |
| | ២.២. បទពិសោធន៍របស់ក្រុមផលិត ក្នុងការលក់ផលិតផលរបស់ខ្លួនរួមគ្នាជាក្រុម<br>Experience of PO to market their products together as a group | 5 | 3 | 4 | 3 | 3 | 4 | 4 | 3 | 3 | 3.4 | គួរឱ្យចាប់អារម្មណ៍ខ្លាំង = ៥;<br>ល្អប្រសើរ = ៤;<br>ល្អ = ៣;<br>ខ្លះៗ = ២,<br>ខ្សោយ = ១ |
| | ២.៣. BPr នីមួយៗ របស់ DPr មានភ្ជាប់មកជាមួយនូវ លិខិតបញ្ជាក់ពីចេតនា ក្នុងការ ទិញពីអ្នកទិញដែលមានសក្ដានុពល Each BPI of the DPr is supported by a letter of intent of purchase by a potential buyer. | 5 | 4 | 5 | 3 | 4 | 5 | 3 | 4 | 4 | 4.0 | DPr មានលិខិតបញ្ជាក់ពីចេតនា ១០០% = ៥;<br>DPr មានលិខិតបញ្ជាក់ពីចេតនាលើសពី ៥០% = ៤<br>DPr មានលិខិតបញ្ជាក់ពីចេតនា ៥០%= ៣<br>DPr មានលិខិតបញ្ជាក់ពីចេតនាតិចជាង ៥០%= ២<br>DPr ពុំមានលិខិតបញ្ជាក់ពីចេតនា ០%=១ |
| **៣. ការរៀបចំDPr/ BPr** | | | | | | | | | | | | |
| | ៣.១. ការជ្រើសរើសការវិនិយោគដែលមានផលិតភាពនៅក្នុង BPr របស់ក្រុមផលិត និងកសិករពាណិជ្ជកម្ម និងសមាគម ត្រូវបានជ្រើសរើសបានល្អ ដែលនឹងអាចសម្រេចបាននូវគោលបំណង របស់ DPr និង BPr ព្រមទាំងគោលបំណងអភិវឌ្ឍន៍របស់គម្រោង (Productive investment in BPI for POs and SMAs are well chosen to achieve the objective of the DPr and BPI and the development objective of the Project.) | 10 | 6 | 3 | 6 | 6 | 6 | 6 | 8 | 6 | 6.5 | ទាំងស្រុង (Totally) = ១០;<br>ច្រើន (substantially) = ៨;<br>ភាគច្រើន (mostly) = ៦;<br>ល្មមគ្រប់គ្រាន់ (just enough) = ៤;<br>មិនគ្រប់គ្រាន់ (not enough) = ២ |
| | ៣.២. សំណើ BPr នៅក្នុង DPr ពិតជាមានដាក់បញ្ចូលនូវ ដំណើរការ ក្នុងកម្រិតកសិដ្ឋាន, ប្រមូលផ្ដុំ, កែច្នៃ និងទីផ្សារ ដែលមានលក្ខណៈពាណិជ្ជកម្ម ដោយប្រើប្រាស់បច្ចេកវិទ្យា ដែលមានលក្ខណៈនវានុវត្តន៍ BPr in DPr include/s innovative technological and commercial processes at farm, aggregation, processing and marketing level. | 5 | 4 | 4 | 3 | 4 | 3 | 4 | 4 | 3 | 3.6 | ទាំងស្រុង (Totally) = ៥;<br>ច្រើន (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៣.៣. សំណើ BPr នៅក្នុង DPr មានការកំណត់ច្បាស់លាស់ ការបន្ថែមតម្លៃលើ ផលិតផល កសិកម្មបឋម តាមរយៈការកែច្នៃ/ កែប្រែ ឬការតម្រៀប ការជ្រើសរើស និងការធ្វើចំណាត់ថ្នាក់ផលិតផល តាមរយៈការវេចខ្ចប់ និងបិទស្លាកសញ្ញា ជាដើម BPr in DPr propose/s adding value to primary production through transformation/processing, or through product sorting and selection by physical traits and/or packing, packaging and/or labelling. | 5 | 3 | 3 | 4 | 3 | 3 | 4 | 4 | 4 | 3.5 | ទាំងស្រុង (Totally) = ៥;<br>ច្រើន (substantially)= ៤;<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough)= ១ |
| ៣.៤. សំណើវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវបានជ្រើសរើសយ៉ាងត្រឹមត្រូវ ដើម្បីគាំទ្រដល់ការ សម្រេចគោលបំណង DPr និងគោលបំណងអភិវឌ្ឍន៍<br>របស់គម្រោង ហើយថវិកា ដែលស្នើឡើងមានលក្ខណៈ សមស្រប Supporting public investments are well chosen to support achieving the objective of the DPr and the development objective of the Project, and are within acceptable budget | 5 | 3 | 5 | 3 | 4 | 5 | 3 | 4 | 3 | 3.8 | **ក. ការវាយតម្លៃដាក់ពិន្ទុប្រសិនបើសហគមន៍បានស្នើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ:**<br>ទាំងស្រុង (Totally)= ៥<br>ច្រើន (substantially)= ៤;<br>ភាគច្រើន (mostly)= ៣;<br>**ខ. ការវាយតម្លៃដាក់ពិន្ទុប្រសិនបើសហគមន៍បានស្នើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ:**<br>ពិន្ទុផ្តល់ឱ្យ÷ ៣ |
| ៣.៥. BPr នៅក្នុង DPr មាន អំណះអំណាងគ្រប់គ្រាន់ដែលបញ្ជាក់ថា ទីផ្សារគោលដៅសម្រាប់ផលិតផល/ សេវាកម្ម ដែលបានស្នើឡើង កំពុងមាន ការកើនឡើង The BPr under the DPr is/are supported by evidence that the targeted market for proposed products/services is growing. | 5 | 3 | 4 | 4 | 3 | 4 | 4 | 4 | 4 | 3.8 | ទាំងស្រុង (Totally) = ៥;<br>ច្រើន (substantially)= ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៣.៦. BPr នៅក្នុង DPr បានកំណត់បញ្ចូលនូវការអនុវត្តកសិកម្មល្អ (GAP) និង ការអនុវត្តល្អក្នុងការផលិតរោងចក្រ/ សហគ្រាស/ សិប្បកម្ម/ កន្លែងកែច្នៃ ផលិតផលកសិកម្ម (GMP) BPr under DPr explicitly incorporate good agricultural practices and good manufacturing practices | 5 | 3 | 3 | 3 | 3 | 3 | 3 | 5 | 3 | 3.3 | ទាំងពីរ (Both) = ៥;<br>ឬមួយក្នុងចំណោមទាំងពីរ (One of them) = ៣;<br>មិនមានមួយណា (none)= ១ |
| **៤. ឧបសគ្គ និងហានិភ័យ ដែលនឹងត្រូវធ្វើការឆ្លើយតប** | | | | | | | | | | | |
| តើមានការរៀបរាប់អំពីហានិភ័យ ដែលសហគមន៍/ ក្រុមផលិត/ កសិករកិច្ចព្រមព្រៀង និងអ្នក កំពុងជួបប្រទះនាពេលបច្ចុប្បន្ន និងវិធានការដើម្បីកាត់បន្ថយហានិភ័យទាំងនោះដែរឬទេ? Are current risks and mitigation measures well formulated? | 5 | 3 | 2 | 4 | 4 | 2 | 4 | 4 | 3 | 3.3 | ទាំងស្រុង (Totally) = ៥;<br>ច្រើន (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| **៥. ការវិភាគហិរញ្ញវត្ថុ** | | | | | | | | | | | |
| លទ្ធភាពទទួលបានផលចំណេញជាមធ្យមសម្រាប់ការវិនិយោគដែលបានស្នើឡើងដោយ PO និង SMA ដែលត្រូវបានបង្ហាញជាអត្រាផលចំណេញសុទ្ធ ដែលស្មើនឹង ផលចំណេញសុទ្ធ ចៀកនឹងចំណូលពីការលក់ (Net Margin = Net Profit/ Revenues) Average financial viability for proposed investment of POs and SMAs expressed in Net Margin (= Net Profit / Revenues) | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5.0 | លើស ១០% (More than 10%) = ៥<br>រហូតដល់ ១០% (Up to 10%) = ៣<br>រហូតដល់ ៥% (Up to 5%) = ១ |
| **៦. ផលប៉ះពាល់ផ្នែកបរិស្ថាន** | | | | | | | | | | | |
| តើគម្រោងនេះផ្តល់ផលប៉ះពាល់អ្វីខ្លះដល់បរិស្ថាន? What is the impact of the project on the environment? | 5 | 4 | [illegible] | 3 | 4 | 4 | 3 | 4 | 3 | 3.6 | វិជ្ជមានខ្ពស់ (Very Positive) = ៥;<br>វិជ្ជមាន (Positive) = ៤;<br>វិជ្ជមានដែរ (rather positive) = ៣;<br>កណ្តាល (Neutral) = ២;<br>អវិជ្ជមាន(Negative)= ១ |
| **៧. ផលប៉ះពាល់ផ្នែកសង្គមរបស់គម្រោង** | | | | | | | | | | | |
| ៧.១. តើបានបញ្ជាក់ច្បាស់លាស់ពីផលប៉ះពាល់អវិជ្ជមានផ្នែកសង្គម កើតចេញពីគម្រោងដែរឬទេ? Are adverse social impacts identified ៧.១. តើបានបញ្ជាក់ច្បាស់លាស់ពីផលប៉ះពាល់អវិជ្ជមានផ្នែកសង្គម កើតចេញពីគម្រោងដែរឬទេ? Are adverse social impacts identified? | 5 | 3 | 3 | 3 | 3 | 3 | 3 | 3 | 4 | 3.1 | ទាំងស្រុង (Totally) = ៥; ភាគច្រើន (mostly)= ៣; មិនគ្រប់គ្រាន់ (not sufficiently) = ១ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ជ.២. តើ DPr នេះបានបង្កើតការងារថ្មីៗដែរឬទេ? (ការងារអចិន្ត្រៃយ៍ និងការងារតាមរដូវកាល) Does the DPr create new jobs (permanent and seasonal) | 5 | 2 | 2 | 3 | 3 | 4 | 3 | 2 | 4 | 2.9 | ជាង ២០ នាក់ = ៥;<br>ចន្លោះ ១០ និង ២០ នាក់ = ៤;<br>ចន្លោះ ៥ និង ១០ នាក់ = ៣;<br>ចន្លោះ ១ និង ៥ នាក់ = ២;<br>មិនបានបង្កើតការងារឡើយ (none) = ១ |
| ជ.៣. តើ DPr នេះ មានផែនការជាក់លាក់ដើម្បីធានាថាស្ត្រី យុវជន និងក្រុមងាយរងគ្រោះផ្សេងទៀតនឹងទទួលបានផលប្រយោជន៍ពីគម្រោង ដែរឬទេ? Does the DPr has concrete plans how to make sure that women and youth and other vulnerable groups will benefit from the Project? | 5 | 3 | 2 | 3 | 3 | 3 | 3 | 3 | 4 | 3.0 | ទាំងស្រុង (Totally)= ៥;<br>ច្រើន(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough)= ១ |
| ជ.៤. BPr និងសំណើខ្សែសង្វាក់តម្លៃ ដែលបានជ្រើសរើស មាននិន្នាការទៅនឹងអាហារូបត្ថម្ភ (Nutrition Sensitive) ឬទេ ហើយសំណើទាំងនេះ អាចត្រូវបានកំណត់ថាជាសំណើដែលអាចរួមចំណែកដល់ការកាត់បន្ថយកង្វះអាហារូបត្ថម្ភ ក្នុងចំណោមប្រជាជនកម្ពុជាដែរឬទេ? Are the BPI and selected value chains nutrition-sensitive and can they be defined as those that can contribute to reducing undernutrition in the Cambodian population ជ.៤. BPr និងសំណើខ្សែសង្វាក់តម្លៃ ដែលបានជ្រើសរើស មាននិន្នាការទៅនឹងអាហារូបត្ថម្ភ (Nutrition Sensitive) ឬទេ ហើយសំណើទាំងនេះ អាចត្រូវបានកំណត់ថាជាសំណើដែលអាចរួមចំណែកដល់ការកាត់បន្ថយកង្វះអាហារូបត្ថម្ភ ក្នុងចំណោមប្រជាជនកម្ពុជាដែរឬទេ? Are the BPI and selected value chains nutrition-sensitive and can they be defined as those that can contribute to reducing undernutrition in the Cambodian population? | 5 | 4 | 2 | 3 | 3 | 4 | 2 | 3 | 4 | 3.1 | ទាំងស្រុង (Totally)= ៥;<br>ច្រើន(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ជ.៥. តើ BPr និងសំណើខ្សែសង្វាក់តម្លៃផ្តោតទៅលើការនាំចេញ ហើយសំណើទាំងនេះអាចត្រូវបានកំណត់ថាជាសំណើដែលអាចរួមចំណែកដល់ការជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា ដែរឬទេ? Are the BPI and selected value chains export-oriented and can they be defined as those that can contribute to promoting Cambodia"s exports of agricultural products? | 5 | 3 | 4 | 4 | 3 | 4 | 4 | 4 | 3 | 3.6 | ទាំងស្រុង (Totally)= ៥;<br>ច្រើន(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| **Total Score** | 100 | 68 | 72 | 69 | 70 | 74 | 70 | 76 | 71 | 71.3 | |

# គណៈកម្មការវាយតម្លៃ "សំណើពិពិធកម្មនិងធុរកិច្ច របស់សហគមន៍កសិកម្មសាមគ្គីរុងរឿង"

| ល.រ | ចំណុចត្រូវវាយតម្លៃ | ពិន្ទុអតិបរមា | ពិន្ទុផ្តល់ដោយសមាជិក | | | | | | | | | សេចក្តីពន្យល់ពីការដាក់ពិន្ទុ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | EC1 | EC2 | EC3 | EC4 | EC5 | EC6 | EC7 | EC8 | Average Score | |
| **១. ភាពពាក់ព័ន្ធនៃDPr ជាមួយក្របខ័ណ្ឌគម្រោង** | | | | | | | | | | | | |
| | ១.១. សនិទានភាព (មូលហេតុ) និងគោលដៅ DPr ដែលស្នើត្រូវបានរៀបចំបានល្អ The rationale and objectives of the proposed DPr are well formulated | 5 | 3 | 4 | 4 | 3 | 4 | 4 | 4 | 3 | 3.6 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥; យ៉ាងច្រើន (substantially)= ៤ ល្អ (good) = ៣; ខ្លះៗ (Some) = ២, ខ្សោយ (poor) = ១ |
| | ១.២. ភាពពាក់ព័ន្ធរបស់DPr នេះ នឹងជួយសម្រេចគោលបំណងគម្រោង CASDP The relevance of the proposed DPr to reach the objective of the CASDP project | 5 | 4 | 4 | 4 | 4 | 4 | 3 | 4 | 3 | 3.8 | គួរឱ្យចាប់អារម្មណ៍ខ្លាំង (impressive) = ៥; យ៉ាងច្រើន (substantially) = ៤; ល្អ (good) = ៣; ខ្លះៗ (some) = ២, ខ្សោយ (poor) = ១ |
| **២. បទពិសោធន៍របស់គូរអង្គពាក់ព័ន្ធ** | | | | | | | | | | | | |
| | ២.១. ចំនួនឆ្នាំពិតជាមធ្យមនៃការប្រកបអាជីវកម្មរបស់ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យម ដែលបានចុះបញ្ជី Average year of legal constitution of POs and SMAs | 5 | 4 | 4 | 4 | 5 | 4 | 4 | 4 | 4 | 4.1 | លើសពី ៣ ឆ្នាំ = ៥; ចន្លោះពី ២ ទៅ ៣ ឆ្នាំ = ៤; ចន្លោះពី ១ ទៅ ២ ឆ្នាំ = ៣; ចន្លោះពី ០,៥ ទៅ ១ ឆ្នាំ = ២; តិចជាង ០,៥ ឆ្នាំ = ១ |
| | ២.២. បទពិសោធន៍របស់ក្រុមផលិត ក្នុងការលក់ផលិតផលរបស់ខ្លួនរួមគ្នាជាក្រុម Experience of PO to market their products together as a group | 5 | 3 | 4 | 3 | 3 | 4 | 3 | 3 | 3 | 3.3 | គួរឱ្យចាប់អារម្មណ៍ខ្លាំង = ៥; យ៉ាងច្រើន = ៤; ល្អ = ៣; ខ្លះៗ = ២, ខ្សោយ = ១ |
| | ២.៣. BPr នីមួយៗ របស់ DPr បានភ្ជាប់មកជាមួយនូវ លិខិតបញ្ជាក់ពីចេតនាក្នុងការ ទិញពីអ្នកទិញសក្តានុពល Each BPl of the DPr is supported by a letter of intent of purchase by a potential buyer. | 5 | 3 | 5 | 3 | 4 | 5 | 4 | 4 | 4 | 4.0 | DPr បានលិខិតបញ្ជាក់ពីចេតនា ១០០% = ៥; DPr បានលិខិតបញ្ជាក់ពីចេតនាលើសពី៥០% = ៤ DPr បានលិខិតបញ្ជាក់ពីចេតនា ៥០%= ៣ DPr បានលិខិតបញ្ជាក់ពីចេតនាតិចជាង ៥០%= ២ DPr ពុំបានលិខិតបញ្ជាក់ពីចេតនា ០%=១ |
| **៣. ការរៀបចំDPr/ BPr** | | | | | | | | | | | | |
| | ៣.១. ការជ្រើសរើសការវិនិយោគដែលមានផលិតភាពនៅក្នុង BPr របស់ក្រុមផលិត និងកសិធុរកិច្ចខ្នាតតូច និងមធ្យមត្រឹមត្រូវ និងសមស្រប ដែលនឹងអាចសម្រេច បាននូវគោលដៅ របស់ DPr និង BPr ហើយ និងគោលដៅអភិវឌ្ឍន៍របស់គម្រោង (Productive investment in BPl for POs and SMAs are well chosen to achieve the objective of the DPr and BPl and the development objective of the Project.) | 10 | 6 | 8 | 6 | 6 | 6 | 6 | 8 | 6 | 6.5 | ទាំងស្រុង (Totally) = ១០; ច្រើន (substantially) = ៨; ភាគច្រើន (mostly) = ៦; ល្មមគ្រប់គ្រាន់ (just enough) = ៤; មិនគ្រប់គ្រាន់ (not enough) = ២ |
| | ៣.២. សំណើ BPr នៅក្នុង DPr នីមួយៗ បានភ្ជាប់មកជាមួយនូវ ដំណើរការក្នុងកម្រិតកសិដ្ឋាន, ប្រមូលផ្តុំ, កែច្នៃ និងទីផ្សារ ដែលមានលក្ខណៈពាណិជ្ជកម្ម ដោយប្រើប្រាស់ បច្ចេកវិទ្យា ដែលមានលក្ខណៈនវានុវត្តន៍ BPr in DPr include/s innovative technological and commercial processes at farm, aggregation, processing and marketing level. | 5 | 4 | 4 | 3 | 4 | 3 | 3 | 4 | 4 | 3.6 | ទាំងស្រុង (Totally) = ៥; ច្រើន (substantially) = ៤; ភាគច្រើន (mostly) = ៣; ល្មមគ្រប់គ្រាន់ (just enough) = ២; មិនគ្រប់គ្រាន់ (not enough) = ១ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៣.៣. តើលើ BPr នៅក្នុង DPr មានការកែលម្អផ្នែក ការបន្ថែមតម្លៃលើផលិតផល កសិកម្មតាមរយៈការកែច្នៃ ឬការផលិត ការជ្រើសរើស និងការធ្វើចំណាត់ថ្នាក់ផលិតផល តាមរយៈការវេចខ្ចប់ និងការបិទស្លាក សញ្ញា ជាដើម BPr in DPr propose/s adding value to primary production through transformation/processing, or through product sorting and selection by physical traits and/or packing, packaging and/or labelling. | 5 | 3 | 3 | 4 | 3 | 3 | 4 | 4 | 4 | 3.5 | ទាំងស្រុង (Totally) = ៥;<br>ច្រើន (substantially)= ៤;<br>ភាគច្រើន (mostly)= ៣;<br>គ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough)= ១ |
| ៣.៤. តើការវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវបានជ្រើសរើសយ៉ាងត្រឹមត្រូវ ដើម្បីគាំទ្រដល់ការ សម្រេចគោលបំណង DPr និង គោលបំណងអភិវឌ្ឍន៍របស់គម្រោង ហើយថវិកា ដែលស្នើឡើងមានលក្ខណៈ សមស្រប Supporting public investments are well chosen to support achieving the objective of the DPr and the development objective of the Project, and are within acceptable budget | 5 | 4 | 5 | 3 | 4 | 5 | 4 | 4 | 3 | 4.0 | **ក. ការវាយតម្លៃដាក់ពិន្ទុប្រសិនបើសហគមន៍ មានស្នើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ:**<br>ទាំងស្រុង (Totally)=៥<br>ច្រើន (substantially)= ៤;<br>ភាគច្រើន (mostly)= ៣;<br>**ខ. ការវាយតម្លៃដាក់ពិន្ទុប្រសិនបើសហគមន៍ មានស្នើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ:**<br>ពិន្ទុផ្តល់ឱ្យ÷ ៣ |
| ៣.៥. BPr នៅក្នុង DPr មាន ភស្តុតាងបញ្ជាក់ថាទីផ្សារគោលដៅ សម្រាប់ការផ្គត់ផ្គង់ផលិតផល/ សេវាកម្ម ដែលបានស្នើឡើង កំពុងមាន ការកើនឡើង The BPr under the DPr is/are supported by evidence that the targeted market for proposed products/services is growing. | 5 | 3 | 4 | 4 | 3 | 4 | 4 | 4 | 3 | 3.6 | ទាំងស្រុង (Totally) = ៥;<br>ច្រើន (substantially)= ៤;<br>ភាគច្រើន (mostly) = ៣;<br>គ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៣.៦. BPr នៅក្នុង DPr បានបញ្ចូលយ៉ាងច្បាស់ការអនុវត្តកសិកម្មល្អ (GAP) និងការអនុវត្តល្អក្នុងការផលិត/ ការកែច្នៃ/ ដំណើរការ/ ការវេចខ្ចប់ ផលិតផលកសិកម្ម (GMP) BPr under DPr explicitly incorporate good agricultural practices and good manufacturing practices | 5 | 3 | 3 | 3 | 3 | 3 | 3 | 5 | 3 | 3.3 | ទាំងពីរ (Both) = ៥;<br>មួយក្នុងចំណោមទាំងពីរ (One of them) = ៣;<br>មិនមានមួយណា (none)=១ |
| **៤. ឧបសគ្គ និងហានិភ័យ ដែលនឹងត្រូវធ្វើការឆ្លើយតប** | | | | | | | | | | | |
| តើមានការរៀបរាប់អំពីហានិភ័យ ដែលសហគមន៍/ ក្រុមផលិត/ សហគ្រិន អាចជួបប្រទះ និងវិធានការដើម្បីកាត់បន្ថយហានិភ័យទាំងនោះដែរឬទេ? Are current risks and mitigation measures well formulated? | 5 | 3 | 2 | 4 | 4 | 2 | 4 | 3 | 3 | 3.1 | ទាំងស្រុង (Totally) = ៥;<br>ច្រើន (substantially) = ៤;<br>ភាគច្រើន (mostly) = ៣;<br>គ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| **៥. ការវិភាគហិរញ្ញវត្ថុ** | | | | | | | | | | | |
| លទ្ធភាពទទួលបានផលចំណេញជាមធ្យមសម្រាប់ការវិនិយោគដែលបាន ស្នើឡើងដោយ PO និង SMA ដែលត្រូវបានបង្ហាញជាអត្រាផលចំណេញ សុទ្ធ ដែលស្មើនឹង ផលចំណេញសុទ្ធ ធៀបនឹងចំណូលពីការលក់ (Net Margin = Net Profit/ Revenues) Average financial viability for proposed investment of POs and SMAs expressed in Net Margin (= Net Profit / Revenues) | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5 | 5.0 | ជាង ១០% (More than 10%) = ៥<br>រហូតដល់ ១០% (Up to 10%) = ៣<br>រហូតដល់ ៥% (Up to 5%) = ១ |
| **៦. ផលប៉ះពាល់ផ្នែកបរិស្ថាន** | | | | | | | | | | | |
| តើគម្រោងនេះផ្តល់ផលប៉ះពាល់អ្វីខ្លះដល់បរិស្ថាន? What is the impact of the project on the environment? | 5 | 4 | 4 | 3 | 4 | 4 | 3 | 4 | 4 | 3.8 | វិជ្ជមានខ្ពស់ (Very Positive) = ៥;<br>វិជ្ជមាន (Positive) = ៤;<br>វិជ្ជមានដែរ (rather positive) = ៣;<br>អព្យាក្រឹត (Neutral) = ២;<br>អវិជ្ជមាន(Negative)=១ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| **៧. ផលជះផ្នែកសង្គមរបស់គម្រោង** | | | | | | | | | | | |
| ៧.១. តើការបញ្ជាក់ច្បាស់លាស់ពីផលប៉ះពាល់អវិជ្ជមានផ្នែកសង្គម ត្រូវបានកំណត់ដែរឬទេ? Are adverse social impacts identified ៧.១. តើការបញ្ជាក់ច្បាស់លាស់ពីផលប៉ះពាល់អវិជ្ជមានផ្នែកសង្គម ត្រូវបានកំណត់ដែរឬទេ? Are adverse social impacts identified? | 5 | 3 | 3 | 3 | 3 | 3 | 3 | 3 | 3 | 3.0 | ទាំងស្រុង (Totally) = ៥; ភាគច្រើន (mostly)= ៣; មិនគ្រប់គ្រាន់ (not sufficiently) = ១ |
| ៧.២. តើ DPr នេះបានបង្កើតការងារថ្មីៗដែរឬទេ? (ការងារអចិន្ត្រៃយ៍ និង ការងារតាមរដូវកាល) Does the DPr create new jobs (permanent and seasonal) | 5 | 2 | 2 | 3 | 3 | 4 | 3 | 2 | 3 | 2.8 | ជាង ២០ នាក់ = ៥;<br>ចន្លោះ ១០ និង ២០ នាក់ = ៤;<br>ចន្លោះ ៥ និង ១០ នាក់ = ៣;<br>ចន្លោះ ១ និង ៥ នាក់ = ២;<br>មិនមានការងារណាមួយកើតឡើយ (none) = ១ |
| ៧.៣. តើ DPr នេះ មានផែនការជាក់លាក់ដើម្បីធានាថាស្ត្រី យុវជន និង ក្រុមងាយរងគ្រោះផ្សេងទៀតនឹងទទួលបានផលប្រយោជន៍ពីគម្រោង ដែរឬទេ? Does the DPr has concrete plans how to make sure that women and youth and other vulnerable groups will benefit from the Project? | 5 | 3 | 2 | 3 | 3 | 3 | 3 | 4 | 3 | 3.0 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough)= ២;<br>មិនគ្រប់គ្រាន់ (not enough)= ១ |
| ៧.៤. BPr និងខ្សែច្រវាក់តម្លៃ ដែលបានជ្រើសរើស មាននិន្នាការទៅនឹងអាហារូបត្ថម្ភ (Nutrition Sensitive) ឬទេ ហើយខ្សែច្រវាក់ទាំងនោះ អាចត្រូវបានកំណត់ថាជាខ្សែដែលអាចរួមចំណែកដល់ការកាត់បន្ថយកង្វះអាហារូបត្ថម្ភ ក្នុងចំណោមប្រជាជនកម្ពុជាដែរឬទេ? Are the BPI and selected value chains nutrition-sensitive and can they be defined as those that can contribute to reducing undernutrition in the Cambodian population ៧.៤. BPr និងខ្សែច្រវាក់តម្លៃ ដែលបានជ្រើសរើស មាននិន្នាការទៅនឹងអាហារូបត្ថម្ភ (Nutrition Sensitive) ឬទេ ហើយខ្សែច្រវាក់ទាំងនោះ អាចត្រូវបានកំណត់ថាជាខ្សែដែលអាចរួមចំណែកដល់ការកាត់បន្ថយកង្វះអាហារូបត្ថម្ភ ក្នុងចំណោមប្រជាជនកម្ពុជាដែរឬទេ? Are the BPI and selected value chains nutrition-sensitive and can they be defined as those that can contribute to reducing undernutrition in the Cambodian population? | 5 | 4 | 2 | 3 | 3 | 4 | 2 | 3 | 4 | 3.1 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| ៧.៥. តើ BPr និងខ្សែច្រវាក់តម្លៃផ្តោតទៅលើការនាំចេញ ហើយ ខ្សែទាំងនេះអាចត្រូវបានកំណត់ថាជាខ្សែដែលអាចរួមចំណែកដល់ការជំរុញការនាំចេញផលិតផលកសិកម្មកម្ពុជា ដែរឬទេ? Are the BPI and selected value chains export-oriented and can they be defined as those that can contribute to promoting Cambodia"s exports of agricultural products? | 5 | 3 | 4 | 4 | 3 | 4 | 4 | 4 | 3 | 3.6 | ទាំងស្រុង (Totally)= ៥;<br>បង្គួរ(substantially)= ៤<br>ភាគច្រើន (mostly)= ៣;<br>ល្មមគ្រប់គ្រាន់ (just enough) = ២;<br>មិនគ្រប់គ្រាន់ (not enough) = ១ |
| **Total Score** | 100 | 67 | 72 | 69 | 70 | 74 | 69 | 76 | 68 | 70.6 | |

## ៦. សេចក្តីសន្និដ្ឋានរបស់គណៈកម្មការវាយតម្លៃ

យោងតាមលទ្ធផលនៃការវាយតម្លៃ និងការដាក់ពិន្ទុលើសំណើពិពិធកម្មនិងធុរកិច្ចរបស់ **"សហគមន៍កសិកម្មសាមគ្គីរហ័សមានជ័យ"** ដែលទទួលបានពិន្ទុចំនួន **៧១.៣០** និង **"សហគមន៍កសិកម្មសាមគ្គីរុងរឿង"** ដែលទទួលបានពិន្ទុ **៧០.៦០** គឺមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការបន្តរៀបចំសរសេរផែនការពិពិធកម្មនិងធុរកិច្ចលម្អិត។ អាស្រ័យហេតុនេះ សមាជិកគណៈកម្មការ EC ទាំងអស់បានសម្រេច និងឯកភាពបញ្ជូនលទ្ធផលនេះ ជូនទៅគណៈកម្មការប្រឹក្សាយោបល់ និងអនុម័ត (AEC) ធ្វើការពិនិត្យ និងសម្រេចជាផ្លូវការលើលទ្ធផលនៃវាយតម្លៃនេះ ដើម្បីផ្តល់លទ្ធភាពឱ្យសហគមន៍កសិកម្មទាំងពីរអាចរៀបចំផែនការពិពិធកម្មនិងធុរកិច្ចបន្ត។ ទន្ទឹមនេះ គណៈកម្មការ EC ស្នើឱ្យសហគមន៍ទាំងពីរត្រូវរៀបរាប់ឱ្យបានច្បាស់លាស់នូវព័ត៌មានមួយចំនួននៅក្នុងផែនការពិពិធកម្ម ដូចខាងក្រោម÷

- **ពិនិត្យមើលឡើងវិញនូវប្រភេទវិនិយោគដែលបានស្នើឡើង ដោយត្រូវធានាថាប្រភេទវិនិយោគដែលស្នើឡើងមានផលិតភាពនឹងអាចសម្រេចបាននូវគោលដៅដែលបានកំណត់នៅក្នុងសំណើ** ទាំងក្នុងកម្រិតសហគមន៍ និងកម្រិតកសិដ្ឋាន ជាពិសេសការទិញរថយន្ត, ត្រាក់ទ័រ និងគោយន្ត ដែលការវិនិយោគទាំងនេះ មានផលិតភាពពិចក្ខុចក្នុងការសម្រេចគោលដៅនៃសំណើ។ សហគមន៍កសិកម្មអាចពិនិត្យមើលការវិនិយោគថ្មីៗមកជំនួសវិញ ដើម្បីឱ្យមានផលិតភាពជាងនេះ និងអាចធានាបាននូវនិរន្តរភាពនៃអាជីវកម្ម, កំណើនប្រាក់ចំណូល និងកាត់បន្ថយបន្ទុកបំណុលដល់សហគមន៍ និងសមាជិក។
- **ធ្វើការកែសម្រួលនូវការប៉ាន់ស្មានតម្លៃនៃប្រភេទវិនិយោគនីមួយៗ ត្រូវធានាថាការប៉ាន់ស្មានតម្លៃទាំងនោះសមស្របទៅនឹងតម្លៃទីផ្សារបច្ចុប្បន្ន** (ឧ. រថយន្ត, ត្រាក់ទ័រ និងគោយន្តជាដើម)។
- **ពិនិត្យមើលឡើងវិញពីបរិមាណផលិត និងតម្រូវការបញ្ជាទិញ** ត្រូវបញ្ជាក់ឱ្យច្បាស់លាស់អំពីផែនការផលិត និងបរិមាណបញ្ជាទិញ និងចំណែកតម្រូវការទីផ្សារផ្សេងទៀត។ ត្រូវធានាថា ការបញ្ជាទិញមានបរិមាណច្រើនជាង ឬ ស្មើនឹងផែនការផលិតរបស់សហគមន៍។
- ត្រូវដាក់បន្ថែមការកាត់រំលស់សម្ភារៈ និង ចំណាយលើការប្រាក់នៅក្នុងការវិភាគហិរញ្ញវត្ថុ។ ការវិភាគហិរញ្ញវត្ថុត្រូវធ្វើឡើងឱ្យបានត្រឹមត្រូវតាមបច្ចេកទេស ជាពិសេសក្នុងកម្រិតកសិដ្ឋាន(ឧ. ចំនួនសមាជិកដែលត្រូវជ្រើសរើសក្នុងការវិភាគហិរញ្ញវត្ថុ)។
- **ផ្តល់ការវិភាគលើតម្លៃប្រៀបធៀបពីផលចំណេញនៃការទិញ-លក់បច្ចុប្បន្ន** ជាមួយ **ផលចំណេញនៃតម្លៃបន្ថែមពីការវិនិយោគរបស់គម្រោង** (ឧ. ការទិញ-លក់ដោយមិនមានលាងសម្អាត ធៀបទៅនឹង ការទិញ-លក់ដោយមានការលាងសំអាត)។
- **សហគមន៍គួរសម្របសម្រួលឱ្យមានការលក់រួមគ្នា** ដែលអាចជួយបន្ធូរបន្ថយបញ្ហាកង្វះទុនប្រតិបត្តិការ របស់សហគមន៍កសិកម្មក្នុងការទិញគ្រាប់ស្វាយចន្ទីពីសមាជិក។
- **ប្រាក់ឧបត្ថម្ភត្រូតពិនិត្យ** មិនមែនជាការចំណាយវិនិយោគទេ ត្រូវដាក់បញ្ចូលក្នុងការចំណាយប្រតិបត្តិការវិញ។
- **ការបង្កើតការងារ** ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីចំនួនការងារត្រូវបង្កើតថ្មីនៅក្នុងផែនការធុរកិច្ច។

ជាកិច្ចបញ្ចប់ **លោក ឡៅ ប៉ូលីវេត** ប្រធានគណៈកម្មការ EC បានធ្វើការថ្លែងអំណរគុណដល់សមាជិកអង្គប្រជុំទាំងអស់ ដែលបានចូលរួម និងស្នើសុំសមាជិកគណៈកម្មការ EC ចូលរួមកិច្ចប្រជុំបន្ទាប់ **នៅថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ ២០២១** វេលាម៉ោង **០៨ : ៣០** នាទីព្រឹក ក្នុងគោលបំណងបន្តពិនិត្យ វាយតម្លៃ និងដាក់ពិន្ទុលើសំណើពិពិធកម្មនិងសំណើធុរកិច្ចរបស់ **“សហគមន៍កសិកម្មរមទមសាមគ្គីមានជ័យ”** និង **“សហគមន៍កសិកម្មស្មីលើកកម្ពស់កសិករ”**។ **លោកប្រធាន** បានប្រកាសបិទអង្គប្រជុំ នៅថ្ងៃដដែល វេលាម៉ោង ១២ : ០០ នាទី ថ្ងៃត្រង់។

ថ្ងៃពុធ ៩ កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០២១

**លេខាធិការ**

**នៃគណៈកម្មការវាយតម្លៃ**

**ឃាន កុសល**

ថ្ងៃព្រហស្បតិ៍ ១០ កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០២១

**យោបល់**

បានឃើញ និងឯកភាព

**ប្រធានគណៈកម្មការវាយតម្លៃ**

**ឡៅ ប៉ូលីវេត**